ល្បែងកម្សាន្ត

# សរសេររឿងប្រៀបប្រដូចមួយ

ចូរគិតអំពីអ្វីមួយនៅក្នុងដំណឹងល្អដែលប្អូនចង់បង្រៀនដល់អ្នកដទៃ ។ តើវត្ថុ ឬឧទាហរណ៍អ្វីខ្លះដែលប្អូនអាចប្រើដើម្បីបង្រៀនវាបាន ? សូមគូររូប ឬសរសេរអំពីវានៅទីនេះ ។



ឧទាហរណ៍ ៖
សេចក្ដីជំនឿ គឺដូចជាគ្រាប់ពូជមួយគ្រាប់ ពីព្រោះវាអាចលូតលាស់បន្តិចម្ដងៗបាន ។

## សូមធ្វើនំប៉័ងដោយខ្លួនឯង

ទឹកក្ដៅឧណ្ហៗ ១ពែង
ដំបែស្ងួត ២ ១/៤ ស្លាបព្រាកាហ្វេ
ស្ករស ២ស្លាបព្រា
ម្សៅ ៣ពែង
អំបិល ១ ស្លាបព្រាកាហ្វេ
ប្រេងឆា ១/៤ ពែង

១. លាយ ទឹក ដំបែ និងស្ករនៅក្នុងចានគោមមួយ ។ សូមរង់ចាំរយៈពេល ៥ នាទីដើម្បីឲ្យដំបែឡើងពពុះ ។
២. សូមលាយម្សៅ អំបិល និងប្រេងឆា ។
៣. ច្របាច់ម្សៅនោះ ១០ នាទី ។ ដាក់ចូលទៅក្នុងផ្ទាំងដែលបានលាបប្រេង ។ គ្រប ហើយទុកចោលរយៈពេលមួយម៉ោង ។
៤. ច្របាច់ម្សៅចុះក្រោម ហើយទុកចោលរយៈពេល ១០ នាទីទៀត ។ ដុតនំនៅកម្ដៅ ៣៥០°F ( ១៧៥ អង្សាសេ ) សម្រាប់រយៈពេល ៣០–៤០ នាទី ។



ប្អូនអាចប្រើរូបមន្តនេះសម្រាប់សកម្មភាពនៅលើទំព័រ ១១ ។